ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៥៣៥ សហវ.ប្រក

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតសំវិធានធនសម្រាប់ឥណទានយឺតយ៉ាវជាប់សង្ស័យ ចំពោះធនាគារក្នុងស្រុក

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធានស្តីពីការធ្វើសំវិធានធនសម្រាប់ឥណទេយ្យជាប់សង្ស័យរបស់ធនាគារក្នុងស្រុក ស្របតាមកថាខណ្ឌ៤ នៃមាត្រា៦ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅដាក់ចេញនូវបទប្បញ្ញត្តិមួយចំនួនទាក់ទិននឹងការធ្វើសំវិធានធនសម្រាប់ឥណទេយ្យជាប់សង្ស័យ ដើម្បីកំណត់ប្រាក់ចំណូលជាប់ពន្ធ របស់ធនាគារក្នុងស្រុក។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះធនាគារក្នុងស្រុក។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ "ធនាគារ" សំដៅដល់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលស្ថិតក្រោមច្បាប់និងបទប្បញ្ញត្តិក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៥.- ចំណាត់ថ្នាក់ឥណទាន**

ឥណទានសម្រាប់ការធ្វើសំវិធានធន ត្រូវបានបែងចែកស្របតាមច្បាប់និងបទប្បញ្ញត្តិក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា ដូចតទៅ÷

១- ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឥណទានសម្រាប់ការធ្វើសំវិធានធន ត្រូវបានបែងចែកជា ៥ ថ្នាក់គឺ÷

ក- ឥណទានថ្នាក់ "ធម្មតា"

ខ- ឥណទានថ្នាក់ "ឃ្លាំមើល"

គ- ឥណទានថ្នាក់ "ក្រោមស្តង់ដារ"

ឃ- ឥណទានថ្នាក់ "សង្ស័យ"

ង- ឥណទានថ្នាក់ "បាត់បង់"។

២- ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឥណទានសម្រាប់ការធ្វើសំវិធានធន ត្រូវបានបែងចែកជា ៤ ថ្នាក់គឺ÷

ក- ឥណទានថ្នាក់ "ស្តង់ដារ"

ខ- ឥណទានថ្នាក់ "ក្រោមស្តង់ដារ"

គ- ឥណទានថ្នាក់ "សង្ស័យ"

ឃ- ឥណទានថ្នាក់ "បាត់បង់"។

### ប្រការ ៦.- សំវិធានធនសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យធ្វើសំវិធានធននូវឥណទានសម្រាប់ឥណទេយ្យជាប់សង្ស័យ ដូចខាងក្រោម÷

- ឥណទានថ្នាក់ "ក្រោមស្តង់ដារ" ២០% នៃឥណទានដុល
- ឥណទានថ្នាក់ "សង្ស័យ" ៥០% នៃឥណទានដុល
- ឥណទានថ្នាក់ "បាត់បង់" ១០០% នៃឥណទានដុល។

### ប្រការ ៧.- សំវិធានធនសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យធ្វើសំវិធានធននូវឥណទានសម្រាប់ឥណទេយ្យជាប់សង្ស័យ ដូចខាងក្រោម÷

- ឥណទានថ្នាក់ "សង្ស័យ" ៣០% នៃឥណទានដុល
- ឥណទានថ្នាក់ "បាត់បង់" ១០០% នៃឥណទានដុល។

### ប្រការ ៨.- ការកែតម្រូវឥណទានសម្រាប់ឥណទេយ្យដែលបានធ្វើសំវិធានធន

អនុលោមតាមប្រការ៧ នៃប្រកាសនេះ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល ធនាគារក្នុងស្រុក ត្រូវធ្វើការកែតម្រូវឥណទានដែលបានធ្វើសំវិធានធនតាមច្បាប់និងបទប្បញ្ញត្តិក្នុងវិស័យធនាគារ ដោយត្រូវចាត់ទុកជាចំណាយមិនអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធវិញនូវឥណទានដូចខាងក្រោម÷

ក- ឥណទាន "ថ្នាក់ធម្មតា" និង "ថ្នាក់ឃ្លាំមើល" សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ខ- ឥណទាន "ថ្នាក់ស្តង់ដារ" និង "ថ្នាក់ក្រោមស្តង់ដារ" សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

### ប្រការ ៩.- ការប្រមូលបានមកវិញនូវឥណទាន

ធនាគារក្នុងស្រុក ត្រូវបញ្ចូលមកជាប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធវិញ នូវចំនួនទឹកប្រាក់ឥណទានដែលបានកាត់កងជាសំវិធានធនចំពោះឥណទេយ្យជាប់សង្ស័យ រួមទាំង ការប្រាក់ និងបន្ទុកផ្សេងៗ នៅពេលដែលប្រមូលបានមកវិញនូវឥណទេយ្យដែលជាប់សង្ស័យទាំងនោះ។

### ប្រការ ១០.- ពន្ធបន្ថែមនិងការប្រាក់

ពន្ធបន្ថែមនិងការប្រាក់ដែលជាប់ទាក់ទិននឹងការកែតម្រូវសំវិធានធនដូចមានចែងក្នុងប្រកាសនេះ ត្រូវបានអនុគ្រោះ ចំពោះការកែតម្រូវទាំងឡាយដែលមានពីពេលមុនរហូតមកដល់ថ្ងៃចូលជាធរមាននៃប្រកាសនេះ វៀរលែងតែការកែតម្រូវណាមួយដែលបានបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់រួចរាល់ហើយ។

### ប្រការ ១១.- ទោសទណ្ឌ

បន្ថែមលើទោសទណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ក្នុងករណីដែលមានការបន្តធ្វើសំវិធានធនដែលមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃប្រកាសនេះ ឬច្បាប់និងបទប្បញ្ញត្តិក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុរបស់

ព្រះរាជាណាចក្រកម្ពុជា ធនាគារក្នុងស្រុកនោះ នឹងមិនត្រូវបានអនុញ្ញាតឱ្យធ្វើសំវិធានធនក្នុងឆ្នាំជាប់ពន្ធដែលមានការបន្ថែមនោះទេ។

**ប្រការ ១២.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ធនាគារក្នុងស្រុក ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ១២ “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ